# ស្ទឹងកំពង់ស្នាច់ A1



**ខេត្ត** : កំពត និង ក្រុងព្រះសីហនុ

**ស្រុក** : កំពត និង ព្រៃនប់

**ផ្ទៃដី ( ហិកតា)** : ១៣.៧៩០

**រយៈកំពស់ ( ម៉ែត្រ)** : 0 ដល់ ១៥៣

**កូអរដោនេចំណុចកណ្តាល** : ១0°៣៧´ជ ១0៣°៥១´ក

**ការពិពណ៌នាទីកន្លែង**

តំបន់ IBA នេះ រួមមានមាត់ពាមស្ទឹងកំពង់ស្នាច់ដែលហូរធ្លាក់ចូលឈូងសមុទ្រនៃប្រទេសថៃទៅទិសខាងកើតនៃឧទ្យានជាតិបូកគោ ។ នៅតាមមាត់ស្ទឹងនេះ មានព្រៃកោងកាងលាតសន្ធឹងធំល្វឹងល្វើយ និង មានវាលភក់ទទួលទឹកជោរនាច រីឯនៅខាងលើមាត់ទន្លេ មានព្រៃស្នាច់ និង ព្រៃកោងកាងប្រភេទ *Nypa* ។ ព្រៃកោងកាងនៅប៉ែកខាងលិចត្រូវទទួលរងនូវការកាប់រានដីព្រៃសម្រាប់ការធ្វើកសិកម្មដំណាំស្រូវ ប៉ុន្តែមាត់ពាមប៉ែកខាងកើតមានព្រៃកោងកាងស្ថិតនៅក្នុងស្ថានភាពល្អដែលមាននៅសេសសល់ដើមធំៗច្រើន ។ តំបន់នេះមានសារៈសំខាន់ណាស់សម្រាប់ប្រភេទសត្វស្លាបសមុទ្រអន្តោប្រវេសន៍ រួមមានខ្វែកសមុទ្រតូចពណ៌ត្នោត ។ ជាងនេះទៅទៀត តំបន់នេះក៏បានទ្រទ្រង់ប្រភេទសត្វស្លាបទឹកមួយចំនួនទៀតនៅក្នុងរយៈពេលនៃរដូវមិនបន្តពូជ រួមមានត្រដក់តូច រនាលពណ៌ រនាលស ទុងប្រផេះ ។ ជាសំខាន់បំផុតនោះ គឺការកត់ត្រាបានត្រដក់ធំចំនួន២២ក្បាលនៅឆ្នាំ ១៩៩៤ ទោះបីជាប្រភេទនេះពុំមានកំណត់ត្រានាពេលថ្មីៗនេះក៏ដោយ ហើយវាជាប្រភេទដែលមិនអាចមានវត្តមានទៀងទាត់ក្នុងតំបន់នេះក្នុងចំនួនមួយពិសេសឡើយ ។

**ប្រភេទសត្វស្លាបសំខាន់ៗ**

| ឈ្មោះខ្មែរ | ឈ្មោះអង់គ្លេស | ឈ្មោះវិទ្យាសាស្ត្រ | លក្ខណៈវិនិច្ឆ័យIBA |
|---|---|---|---|
| ខ្វែកសមុទ្រតូចពណ៌ត្នោត | Asian Dowitcher | *Limnodromus semipalmatus* | A1 |
| ត្រដក់តូច | Lesser Adjutant | *Leptoptilos javanicus* | A1 |
| ត្រដក់ធំ | Greater Adjutant | *Leptoptilos dubius* | A1 |
| ទុងប្រផេះ | Spot-billed Pelican | *Pelecanus philippensis* | A1 |
| រនាលពណ៌ | Painted Stork | *Mycteria leucocephala* | A1 |
| រនាល ស | Milky Stork | *Mycteria cinerea* | A1 |

**ការគំរាមកំហែងលើជីវៈចំរុះ**

ព្រៃកោងកាងដុះតាមមាត់ឆ្នេរប៉ែកខាងលិចបានថយចុះយ៉ាងខ្លាំងដោយសារការទន្ទ្រានយកដី និង ការប្រែក្លាយដីព្រៃសម្រាប់ការធ្វើកសិកម្មដំណាំស្រូវដែលជាផ្នែកមួយនៃគំរោងអភិវឌ្ឍន៍យ៉ាងចំបងទាក់ទងទៅនឹងការស្ថាបនា និង ការស្តារឡើងវិញនៃទំនប់ទឹក ។ ព្រៃកោងកាងដែលដុះនៅប៉ែកខាងកើតនៃតំបន់មាត់ពាមមានលក្ខណៈល្អប្រសើរ ហើយតំបន់មួយចំនួននៅប៉ែកខាងត្បូងត្រូវបានគេប្រែក្លាយដីព្រៃទៅជាដីកសិកម្ម ។ នៅប៉ែកខាងលើស្ទឹងព្រៃស្នាច់ និង ព្រៃកោងកាងជាច្រើនត្រូវបានកាប់ធ្វើជាបង្គោល និង ដុតយកធ្យូង ។

### អនុសាសន៍

ត្រូវធ្វើយ៉ាងណាឱ្យបានប្រាកដថា ផលប៉ះពាល់បរិស្ថានទាំងឡាយត្រូវបានត្រួតពិនិត្យ និង ស្វែងយល់ឱ្យបានច្បាស់ លាស់ មុននឹងធ្វើការប្រែក្លាយដីព្រៃកោងកាង និង តំបន់ដីសើមក្បែរៗទៅជាដីកសិកម្ម ។

ការអង្កេតចាំបាច់ត្រូវធ្វើឡើងថែមទៀតទៅកាន់តំបន់វាលភក់ និង តំបន់ព្រៃកោងកាង ដើម្បីធ្វើអត្តសញ្ញាណកម្ម និង ស្វែងយល់អំពីតំបន់សំខាន់ៗ និង ការប្រើប្រាស់តំបន់ដោយសត្វស្លាបទឹកធំៗ និង សត្វស្លាបសមុទ្រអន្តោប្រវេសន៍ផ្សេងៗទៀត ។

### ឯកសារយោង

Edwards, P. J. (1996) *Cambodia wetlands ornithological survey*. Newmarket: Xenus Ecology.

Edwards, P. J. (1996) Recent waterbird surveys in Cambodia. *Forktail* 15: 29-42.

Goes, F. Tan Setha and Ros Bansok (1998) *Preliminary bird survey for cluster of three national parks in southern C ambodia.* Phnom Penh: European Commission Support Programme to the Environment Sector in C ambodia.

Mundkur, T., Carr, P., Sun Hean and Chhim Somean (1995) *Surveys for large waterbirds in Cambodia, March-Apri l 1994.* Cambridge, UK: IUCN/SSC.